# ការសំភាសន៍របស់លោកពូ ឃុន ពេជ្រ

កៈ អ្នកធ្វើការសំភាសន៍ដោយ គីម ម៉េង ខៈ អ្នកដែលត្រូវបានគេសំភាសន៍ពូ ឃុន ពេជ្រ

**<u>ការសង្ខេបរបស់លោក ឃុន ពេជ្រ</u>**

លោកពូ ឃុន ឃុន ពេជ្រគាត់មានអាយុ ៥៩ឆ្នាំ ក្នុងឆ្នាំ ២០១៨ លោកពូ ឃុន ពេជ្រ គាត់មានភេទ ប្រុសលោកពូ ឃុន ពេជ្រ មានទីលំនៅនាពេលបច្ចុប្បន្ននៅភូមិក្រោកគោ សង្កាត់គីឡូម៉ែត្រលេខ ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

កៈ

ចឹងជាដំបូងជំរាបសួរលោកពូខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ជើញដើម្បីមានការសំភាសន៍លោកពូអំពីពង្សប្រវត្តិតតើលោកពូអាយអនុញ្ញាត្តិអោយសំភាសន៍លោកយាយពង្សប្រវត្តិលោកពូបានដែលទេ៕

ខៈ បាទបាន ៕

កៈ

ចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៍លោកពូគឺជាថ្ងៃទី២៨ខែ៤(មេសា)ឆ្នាំ២០១៨ហើយធ្វើការសំភាសន៍ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៍លោកពូឈ្មោះ ឃុន ពេជ្រចឹងផ្តើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះរបស់លោកពូបានដែលទេលោកពូ ???

ខៈ បាទបានខ្ញុំឈ្មោះ ឃុន ពេជ្រ៕

កៈ

បាទហើយចឹងសំណួរដែលខ្ញុំដែលចង់សួរលោកពូដំបូងសួរលោកពូដំបូងឈ្មោះពេញរបស់លោកពូតែម្តងថាតើលោកពូមានឈ្មោះអ្វីដែលទៅលោកពូឈ្មោះពេញរបស់លោកពូហាសហើយនឹងត្រកូលរបសប់លោកពូហាស???

ខៈ

បាទនិយាយពីត្រកូលទាំងអីហាសបាទទាំងជីទូតទាំងអីនឹងហាសបាទសំរាប់នាមត្រកូលរបស់ខ្ញុំនឹងគឺឈ្មោះថា ឃុន ពេជ្រ៕

កៈ បាទហើយចឹងថាតើលោកពូមានឈ្មោះហៅក្រៅដែលរឺទេលោកពូ???

ខៈ បាទគឺគ្មាននោះទេបាទ៕

កៈ បាទហើយសំរាប់លោកពូឆ្នាំនឹងលោកពូមានអាយុប៉ុន្មានឆ្នាំហើយទៅលោកពូ???

ខ៖ បាទសំរាប់ខ្ញុំនឹងប្រសិនជាគិតទៅខ្ញុំនឹងប្រហែលជា ៥៩ឆ្នាំ ហើយប្រសិនជាគិតទៅហាសរឺក៏ចូលដល់ ៦០ឆ្នាំ បាទនិយាយទៅខ្ញុំនឹងចូលដល់ ៦០ឆ្នាំហើយបាទ៕

ក៖ បាទហើយចឹងលោកពូចូលដល់ អាយុ៥៩ឆ្នាំហើយបាទហើយចឹងលោកពូមានទីកន្លែងកំណើតនៅទីកន្លែងណាដែលទៅលោកពូ???

ខ៖ បាទសំរាប់ខ្ញុំនឹងមានទីកន្លែងកំណើតនៅខាងព្រៃវែងហាសបាទ៕

ក៖ បាទទីកន្លែងកំណើតរបស់លោកពូមានភូមិអ្វីស្រុកអ្វីហើយនឹងខេត្តអ្វីដែលទៅលោកពូ???

ខ៖ បាទសំរាប់ស្រុកនឹងកាល់ពីដើមនឹងគេបានហៅស្រុកនឹងថាគឺជាស្រុកព្រៃវែងចឹងហាសបាទស្រុកព្រៃវែងហើហាយនឹងខេត្តព្រៃវែងបាទដល់ពេលមកដល់ពេលបច្ចុប្បន្ននឹងគឺគេបានហៅថាស្រុកស្វាយអន់ទរខេត្តព្រៃវែងបាទហើយគឺឃុំទឹកថ្លាបាទ និយាយទៅគឺគេហៅថាភូមិទួលអំពិល ឃុំទឹកថ្លា ស្រុកស្វាយអន់ទរ ខេត្តព្រៃវែង បាទ៕

ក៖ បាទហើយចឹងអរគុណច្រើនមែនទែនលោកពូហើយចឹងសំរាប់លោកពូថាតើលោកពូមានបងប្អូននឹងចំនួនប៉ុន្មាននាក់ទៅលោកពូ???

ខ៖ បាទសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងមានបងប្អូននឹងចំនួន ៥នាក់ បាទហើយពួកគាត់ទាំងអស់នឹងបានស្លាប់ចំនួន ៣នាក់ហើយគឺនៅសល់ ២នាក់បាទ៕

ក៖ បាទហើយចឹងសំរាប់លោកពូថាតើលោកពូគឺជាកូនទីប៉ុន្មានដែលទៅលោកពូ???

ខ៖ បាទសំរាប់ខ្ញុំគឺខ្ញុំនឹងគឺជាកូនទី ៣ បាទខ្ញុំនឹងគឺជាកូនទី៣ ៕

ក៖ បាទហើយចឹងសំរាប់លោកពូមាននៅចងចាំឈ្មោះបងប្អូនរបស់លោកពូទាំងអស់ដែលរឺទេលោកពូ???

ខ៖ បាទបងប្អូនរបស់ខ្ញុំគឺខ្ញុំនៅចាំឈ្មោះរបស់គាត់ទាំងអស់តា៕

ក៖ បាទហើយចឹងលោកពូអាចប្រាប់ឈ្មោះបងប្អូនរបស់លោកពូម្តងម្នាក់ម្តងម្នាក់បានដែលទេលោកពូ???

ខ៖ បាទសំរាប់បងប្អូនរបស់ខ្ញុំនឹងទី១គាត់មានឈ្មោះថា ប៊ុន យ៉ាន (ស្រី)
ហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងទី២គាត់មានឈ្មោះថា ប៊ុន ថា
ហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងទី៣គាត់មានឈ្មោះថា ប៊ុន កួយ
ហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងទី៤គាត់មានឈ្មោះថា ប៊ុន កួយ
ហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងទី៥គាត់មានឈ្មោះថា ប៊ុន ទៀក ៕

ក៖
បាទហើយសំរាប់សំរាប់បងប្អូនរបស់លោកពូនឹងសព្វថ្ងៃនឹងថាតើពួគាត់រស់នៅទីកន្លែងណាដែលទៅលោកពូ???

ខ៖
បាទសព្វថ្ងៃនឹងគឺពួគាត់បានរស់នៅខេត្តព្រៃវែងនឹងតែម្តងហាសបាទហើយពូគាត់រស់នៅជុំគ្នាចឹងហាសក៏ប៉ុនតែមាននាក់ខ្លះនឹងគេបានស្លាប់ខ្លះចឹងហាសបាទគឺពួកគាត់បានស្លាប់អស់ចំនួន២នាក់ហើយចឹងហាសបាទហេអត់ទេគឺស្លាប់អស់ចំនួន៣នាក់បាទ៕

ក៖
បាទហើយចឹងពួកគាត់បានស្លាប់នៅក្នុងជំនាន់ពោលពតរឺក៏ស្លាប់នៅក្នុងជំនាន់នឹងដែលទៅលោកពូ???

ខ៖
បាទនិយាយទៅគឺពួកគាត់នឹងបានស្លាប់នៅក្នុងជំនាន់ពោលពតបាទហើយមួយនឹងគឺជាបងទី២របស់ខ្ញុំនឹងគឺគាត់បានស្លាប់នៅក្នុងជំនាន់ពោលពតហើយសំរាប់បងទី១របស់ខ្ញុំនឹងគឺគាត់បានស្លាប់នៅក្នុងជំនាន់នឹងឯងបានបាទ៕

ក៖
បាទហើយចឹងសំរាប់បច្ចុប្បន្ននឹងថាតើបងរបស់លោកពូនឹងគាត់មានជំងឺអ្វីដែលទៅបានជាគាត់នឹងបានស្លាប់ចឹងទៅលោកពូ???

ខ៖
បាទនៅពេលដែលគាត់បានស្លាប់នឹងគឺជាជំងឺឈឺហើយខ្ញុំនឹងក៏មិនបានដឹងថាគាត់មានជំងឺឈឺអ្វីដែលចឹងហាសតែខ្ញុំនឹងបានលឺគេនិយាយថាគាត់មានជំងឺឈឺដោយសារជំងឺលើសឈាមចឹងហាសបាទហើយដល់ចឹងទៅដូចថាដូចជារអាក់រអួលហើយសំរាប់ជើងរបស់គាត់នឹងគឺគាត់ដើលលេងរួចចឹងទៅហាសបាទហើយនៅពេលដែលគាត់ដើលមិនរួចចឹងទៅយើងក៏បានដាក់គាត់នឹងទៅនឹងរទេះរុនបាទហើយនៅពេលដែលយើងបានយើងក៏បានដាក់គាត់នឹងទៅនឹងរទេះរុនហើយចឹងយើងក៏បានរុនគាត់ទៅបះទៅនឹងអាគ្រែបបរនឹងបាទនៅពេលនឹងគឺគាត់ទៅជាស្ពួកស្ពឹងក្រោកលេងរួចតែម្តងបាទគឺគាត់គ្មានបានទៅឈឺអ្វីនោទេគ្រាន់តែថៅរបស់គាត់នឹងបានរុនគាត់នឹងទៅបះនឹងគ្រែបបរនឹងទៅជាគាត់នឹងដេកស្ពុតស្ពឹងហើយនឹងនិយាយបានតែម្តងហើយនឹងក្រោកលេងរួចអីចឹងទៅហាសបាទ៕

ក៖
បាទហើយចឹងនៅពេលដែលគាត់បានស្លាប់ចឹងថាតើគាត់បានស្លាប់នៅក្នុងអាយុប៉ុន្មានឆ្នាំដែលទៅលោកពូ???

ខ៖ បាទនៅពេលដែលគាត់បានស្លាប់នឹងគឺគាត់បានស្លាប់នឹងនៅក្នុងអាយុ ៦០ឆ្នាំជាហើយក៏ប៉ុនតែខ្ញុំនឹងមិនបានដឹងថា ៦០ប៉ុន្មាននោះទេបាទបាទនិយាយទៅនោពេលដែលគាត់បានស្លាប់នឹងប្រហែល៦៧ឆ្នាំរឺ៦៨ឆ្នាំនឹងហាសបាទ៕

ក៖
បាទហើយចឹងសំរាប់ឪពុកហើយនឹងម្ដាយរបស់លោកពូគាត់មានឈ្មោះអ្វីដែលទៅលោកពូ???

ខ បាទសំរាប់លោកឪពុករបស់ខ្ញុំនឹងគាត់មានឈ្មោះថា ប៊ុន យុន បាទហើយសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺមានឈ្មោះថា នៅយុតបាទ ៕

ក៖
បាទហើយចឹងថាតើលោកទាំង២នឹងឆ្នាំនឹងគាត់មានអាយុប៉ុន្មានឆ្នាំដែលហើយទៅលោកពូ???

ខ៖ បាទប្រសិនជានិយាយទៅគឺគាត់បានស្លាប់យូរហើយចឹងហាសបាទ៕

ក៖
បាទហើយចឹងលោកទាំង២គាត់បាននៅទីស្រុកកំណើតរឺក៏នៅកន្លែងណាផ្សេងដែលទៅលោកពូបាទប្រសិនជាគាត់នៅរស់នឹងហាសលោកពូចឹងគិតថាលោកទាំង២មានអាយុប៉ុន្មានដែលទៅលោកពូ???

ខ៖ បាទសំរាបលោកឪពុករបស់ខ្ញុំនឹងកាល់ដែលបានស្លាប់នឹងគឺនៅក្នុងឆ្នាំ ៧៣ឆ្នាំ បាទហើយម្ដាយរបស់ខ្ញុំនឹងគឺគាត់មានអាយុប៉ុន្មាននោះទេនិយាយទៅប្រហែល៧២ឆ្នាំហើយមើលទៅបាទគឺគាត់បានស្លាប់នឹងជំងឺរបស់គាត់ចុះយើងមិនបានដឹងថាយ៉ាងមិចផងនឹងបាទ៕

ក៖
បាទហើយចឹងសំរាប់ទីកន្លែងកំណើតរបស់លោកទាំង២នឹនងថាតើគាត់រស់នៅទីកន្លែងណាដែលទៅលោកពូ???

ខ៖ បាទសំរាប់លោកឪពុករបស់ខ្ញុំនឹងគាត់បានកើតនីឃុំទួលអំពៅនឹងហាសបាទ ស្រុកទឹកថ្លា និយាយទៅគឺគាត់រស់នៅតាំងពីគាត់នៅពោលពតមកចឹងហាសបាទ៕

ក៖
បាទហើយចឹងលោកទាំង២នឹងគឺគាត់បានទទួលមរណះភាពហើយមែនដែលទេលោកពូ???

ខ៖ បាទនិយាយទៅគឺគាត់បានទទួលមរណះភាព៕

ក៖
បាទចឹងអរគុណច្រើនមែនទែនលោកពូបាទហើយចឹងថាតលោកពូសព្វថ្ងៃនឹងថាតើលោកពូប្រកបមុខរបបអ្វីដែលទៅលោកពូហើយនឹងលោកពូមានភរិយាដែលរឺទេលោកពូ???

ខ៖ បាទសំរាប់សព្វថ្ងៃនឹងគឺខ្ញុំនឹងមានភរិយាយបាទ៕

ក៖ បាទហើយចឹងសំរាប់ភរិយារបស់លោកពូគាត់មានឈ្មោះអ្វីដែលទៅលោកពូ???

ខ៖ បាទសំរាប់ភរិយារបស់ខ្ញុំនឹងគាត់មានឈ្មោះថាចាន់លី៕

ក៖ បាទហើយចឹងសំរាប់ភរិយារបស់លោកពូគាត់មានអាយុប៉ុន្មានឆ្នាំហើយលោកពូ???

ខ៖ បាទសំរាប់ប្រពន្ធរបស់ខ្ញុំនឹងគាត់មានអាយុ៥៨ឆ្នាំហើយចឹងបាទ៕

ក៖
បាទហើយចឹងសំរាប់ទីកន្លែងកំណើតរបស់អ្នកមីងគាត់មានទីកន្លែងកំណើតនៅកន្លែងណាដែលទៅលោកពូ???

ខ៖
បាទសំរាប់ទីកន្លែងកំណើតរបស់ប្រពន្ធរបស់ខ្ញុំនឹងគឺនៅកន្លែងនឹងតែម្តងបាទនៅភូមិជាមួយនឹងគ្នាហាសបាទ៕

ក៖ បាតហើយចឹងលោកពូទាំងអស់គ្នាគឺនៅខេត្តព្រៃវែងនឹងតែម្តងមែនដែលទេលោកពូ???

ខ៖ បាទបាទគឺយើងទាំងអស់គ្នានឹងនៅភូមិជាមួយនឹងគ្នាតែម្តងហាសបាទ៕

ក៖
បាទហើយចឹងសំរាប់លោកពូថាតើលោកពូមានកូនចំនួនប៉ុន្មាននាក់ដែលទៅលោកពូ???

ខ៖
បាទសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងមានកូនច្រើនណាស់បាទប្រសិនជានិយាយទៅគឺខ្ញុំនឹងមានកូន១០ជាងឯនោះទេបាទ៕

ក៖
បាទហើយចឹលោកពូអាចប្រាប់ឈ្មោះកូនរបស់លោកពូទាំងអស់ម្តងម្នាក់ម្តងម្នាក់បានដែលទេលោកពូ???

ខ៖ បាទសំរាប់ខ្ញុំគឺខ្ញុំ
នឹងមិនជាដឹងថាគាត់នៅសល់ប៉ុន្មានទេពីព្រោះអីនឹងគឺខ្ញុំនឹងមិនបានដឹងថាវានៅសល់ប៉ុន្មានអីប៉ុន្មាននឹងនោះទេបាទ៕

ក៖ បាទតែសំរាប់លោកពូមាននៅចងចាំឈ្មោះរបស់គាត់ដែលរឺទេលោកពូ???

ខ៖
បាទសំរាប់ខ្ញុំនឹងគឺខ្ញុំនៅចាំតាបាទនិយាយទៅចាំបានតិចតិចហាសព្រោះអអីនឹងគឺខ្ញុំនឹងកាល់នឹងគឺខ្ញុំនៅតូចពេកចឹងហាសបាទ៕

ក៖
បាទហើយចឹងលោកពូអាចប្រាប់ឈ្មោះរបស់គាត់ទាំងអស់ដែលគាត់កំពុងមានជីវិតរស់នៅនឹងបានដែលទេលោកពូ???

ខ៖
បាទប្រសិនជានិយាយទៅដែលនៅសព្វថ្ងៃនឹងមានចំនួន១០នាក់ចឹងហាសបាទហើយចឹងសំរាប់ឈ្មោះបងប្អូនរបស់ខ្ញុំនឹងទី១គាត់មានឈ្មោះថា  យុន លូត
បងប្អូនរបស់ខ្ញុំនឹងទី២គាត់មានឈ្មោះថា យុន មុំ បងប្អូនរបស់ខ្ញុំនឹងទី៣ គាត់មានឈ្មោះថា យុន ឡា បងប្អូនរបស់ខ្ញុំនឹងទី៤គាត់មានឈ្មោះថា យុន រ៉ា
បងប្អូនរបស់ខ្ញុំនឹងទី៥គាត់មានឈ្មោះថាបងប្អូនរបស់ខ្ញុំនឹងទី៥គាត់មានឈ្មោះថា យុន ទូច
បងប្អូនរបស់ខ្ញុំនឹងទី៦គាត់មានឈ្មោះថា យុន ស្នារ
បងប្អូនរបស់ខ្ញុំនឹងទី៧គាត់មានឈ្មោះថា យុន អូន
បងប្អូនរបស់ខ្ញុំនឹងទី៨គាត់មានឈ្មោះថា យុន ស្រីអូន
បងប្អូនរបស់ខ្ញុំនឹងទី៩គាត់មានឈ្មោះថា យុន អូន
បងប្អូនរបស់ខ្ញុំនឹងទី១០គាត់មានឈ្មោះថា យុន ស្រីពេជ្រ
ហើយគេទាំងអស់គ្នាបានហៅតែស្រីអូនស្រីអូនក៏ទៅតាមនឹងទៅចឹងហាសបាទហេហេហេហេបាទ៕

ក៖
បាទហើយចឹងពួកគាត់ដែលមានឈ្មោះស្រដែងគ្នានឹងគឺគេបានហៅថាស្រីអូនទាំងអស់តែម្តងមែនដែលទេលោកពូ???

ខ៖
បាទនិយាយទៅគឺគេហៅស្រីអូនទាំងអស់តែម្តងបាទហើយសំរាប់ភាគច្រើននឹងគឺគេហៅតែស្រីអូនបាទតែសំរាប់ឈ្មោះរបស់គេនឹងគឺគេឈ្មោះ ស្រី មិច នោះទេបាទ៕

ក៖ បាទហើយចឹងអ្នកទី១០នឹងគាត់មានឈ្មោះ ស្រី មិចមែនដែលទេលោកពូ
បាទហើយចឹងពួកគាត់ទាំង១០នឹងពួកគាត់រស់នៅទីកន្លែងណាដែលទៅលោកពូ???

ខ៖
បាទមួយនោះនឹងគឺគេបានរស់នៅឯងស្មិចឯងនោះបាទដែលជាទីខេត្តបន្ទាយមានជ័យហាសបាទ បាទហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងទី២គាត់បានរស់នៅខាង កំពុងឆ្នាំង បាទហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងទី៣គាត់បានរស់នៅនេះបាទនៅខាងក្រោយនឹងហាសបាទ បាទហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងទី៤គាត់បានរស់នៅខាងព្រៀលអន្លែក ខេត្តព្រៃវែង បាទហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងទី៥គាត់បានរស់នៅនឹងដែល បាទហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងទី៦គាត់បានរស់នៅនឹងដែល ទី៧ទី៨ទី៩ទី១០ គឺនៅទីកន្លែងនឹងទាំងអស់គឺរស់នៅជុំគ្នាទាំងអស់ទាំងអស់បាទបាទហើយសំរាប់ពួកអ្នកដែលនៅជុំគ្នានឹងគឺសុទ្ធតែមិនទាន់ប្រពន្ធនោះទេបាទ៕

ក៖ បាទហើយចឹងទី៧ទី៨ទី៩ទី១០ គឺនៅទីកន្លែងនឹងទាំងអស់គឺរស់នៅជុំគ្នាទាំងអស់បាទហើយចឹងថាតើកូនរបស់លោកពូមួយណាដែលពួកគាត់មានគ្រួសារហើយដែលចឹងហាសលោកពូ???

ខ៖
បាទសំរាប់កូនរបស់ខ្ញុំនឹងដែលពួកគាត់មានគ្រួសារនឹងគឺមានចំនួន៤នាក់ចឹងហាសបាទអត់គឺមានចំនួន៥នាក់បាទបាទហើយសំរាប់នាក់មិនទាន់មានគ្រួសារនឹងក៏មានចំនួន៤នាក់ដែលចឹងហាស៕

ក៖
បាទហើយចឹងកូនរបស់លោកពូដែលមិនបានទាល់មានគ្រួសារនឹងក៏មាន៤នាក់ដែលបាទហើយចឹងរាល់ថ្ងៃនឹងថាតើពួកគាត់នៅសិក្សារឺក៏ធ្វើការងារដែលលោកពូ???

ខ៖
បាទនិយាយទៅគឺគ្មាននាក់ណានៅសិក្សានោះទេគឺទាំងអស់នឹងធ្វើការងារខាងសំណង់អីចឹងទៅបាទហើយក៏មាននាក់ខ្លះទៀតចឹងទៅធ្វើការងាររោងចក្រចឹងទៅហាសបាទ៕

ក៖
បាទហើយចឹងសំរាប់នៅក្នុងក្រុមគ្រួសាររបស់លោកពូថាតើមាននាក់ណាដែលជាអ្នកផ្គត់ផ្គង់នៅក្នុងក្រុមគ្រួសាររបស់លោកពូដែលទៅលោកពូ???

ខ៖
បាទនិយាយទៅគឺយើងទាំងអស់គ្នាដែលរស់នៅក្នុងផ្ទះនឹងគឺយើងទាំងអស់គ្នាបានរួមសម្បគ្នាចឹងទៅបាទមានកូនស្រីនឹងវាបានអោយខ្លះចឹងទៅហើយនឹងកូនប្រុមនឹងក៏បានអោយខ្លះទៀតចឹងទៅសំរាប់កូនស្រីនឹងក៏គេបានធ្វើការងារនៅក្នុងរោងចក្រចឹងទៅសំរាប់កូនប្រុសនឹងគឺគេបានធ្វើការងារសំណង់អីចឹងទៅបាទហើយនៅពេលដែលបានលុយមករួមគ្នាដោះស្រាយថ្លៃទឹកថ្លៃភ្លើងចឹងទៅបាទហើយនឹងម្ហូបសំរាប់ហូបអីចឹងទៅបាទ៕

កៈ
បាទហើយចឹងសំណួរដែលខ្ញុំនឹងចង់សួរទៅកាន់លោកពូមួយទៀតថាតើកាល់ដែលលោកពូនៅពីក្មេងនឹងថាតើលោកពូមានបានសិក្សាដែលរឺទេលោកពូ???

ខៈ
បាទសំរាប់កាល់ដែលខ្ញុំនឹងនៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងមិនទាល់បានសិក្សារៀនសូត្រអ្វីនោះទេបាទយើងគ្រាន់តែយើងបានរៀនអីនឹងបានតែបន្តិចបន្តួចទេហាសបាទចឹងហើយយើងធ្វើការងារអ្វីមិនបាននោះទេពីព្រោះអីយើងនឹងបានរៀនសូត្រតែបន្តិចបន្តួចទេហាសបាទ៕

កៈ បាទហើយសំរាប់លោកពូថាតើលោកពូរៀនបានថ្នាក់ទីប៉ុន្មានដែលហើយលោកពូ???

ខៈ
បាទសំរាប់ខ្ញុំនឹងនៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងរៀនបានតែត្រឹមថ្នាក់ទី៣រឺក៏ទី៤នោះទេបាទ៕

កៈ
បាទហើយនៅក្នុងជំនាន់ពោលពតនឹងរៀនបានតែត្រឹមថ្នាក់ទី៣រឺក៏ទី៤នឹងជាថ្នាក់ធំមែនដែលទេលោកពូបាទដោយសារនៅក្នុងជំនាន់នឹងគេបាននិយាយថាសំរាប់ថ្នាក់ទី១២នឹងគឺជាថ្នាក់តូចជាងគេចឹងហាសមែនដែលទេលោកពូ???

ខៈ បាទសំរាប់ថ្នាក់ទី១២នឹងកាល់ពីសង្គមនឹងវាតូចជាងគេមែមដែលទេ៕

កៈ
បាទខ្ញុំនឹងបានលឺចាស់ចាស់និយាយថាសំរាប់ថ្នាក់ទី១២នឹងកាល់ពីសង្គមនឹងវាតូចជាងគេហើយសំរាប់ថ្នាក់ទី១នឹងគឺធំជាងគេចឹងបានន័យថាលោកពូរៀនបានថ្នាក់ទី៣នឹងគឺវាធំហើយមែនដែលទេលោកពូហេហេហេដោយសារគេបាននិយាយសំរាប់ថ្នាក់ទី១នឹងគេបានប្រលងចប់បាក់ឌុបហើយចឹងហាសហើយចឹងវាយ៉ាងមិចដែលលោកពូអាចប្រាប់ខ្ញុំនឹងបានដែលរឺទេលោកពូ???

ខៈ បាទសំរាប់ថ្នាក់ទី១នឹងទី២នឹងគឺគរចាប់ផ្តើមរៀនា៏ ទៅហាសបាទនឹងហើយ៕

កៈ
បាទហើយចឹងអត់អីទេលោកពូបាទហើយចឹងនៅក្នុងជំនាន់នឹងថាតើលោកពូបានរៀននៅថ្នាក់ទី៣នឹងថាតើលោកពូរៀននឹងគឺជាសិស្សពូកែរឺក៏ជាសិស្សមធ្យមរឺក៏ជាសិស្សមិនសូវពូកែរឺក៏យ៉ាងមិចដែលទៅលោកពូ???

ខៈ បាទសំរាប់នៅក្នុងជំនាន់នឹងគឺខ្ញុំនឹងគឺជាសិស្សមធ្យម៕

កៈ
បាទហើយចឹងមុខវិជ្ជាអ្វីដែលទៅដែលលោកពូបានរៀនបានមធ្យមចឹងហាសលោកពូ???

ខៈ
បាទសំរាប់នៅក្នុងជំនាន់នឹងមុខវិជ្ជាដែលខ្ញុំនឹងបានរៀនពូកែនឹងគឺជាមេលេខបូកហើយនឹងលេខគុណចឹងហាសបាទហើយសំរាប់ភាសាខ្មែរនឹងគឺខ្ញុំនឹងក៏មិនជាសូវរៀនបានពូកែដែលពីព្រោះខ្ញុំក៏មិនមែនជាអ្នករៀនបានច្រើនហើយនឹងបានជ្រៅជ្រះអីនឹងគេដែលចឹងហាសបាទ៕

កៈ
បាទហើយចឹងកាល់នៅក្នុងជំនាន់នឹងថាតើលោកពូមានមិត្តភក្តិណាដែលស្និទស្នាដែលរឺទេលោកពូ???

ខៈ
បាទនិយាយទៅគឺមានដែលចឹងហាសគឺមានតែនៅក្នុងភូមិនោះទេវាមិនដូចល្ងវនឹងណានោះទេពីព្រោះអីយើងនឹងគឺគេនៅភូមិរបស់គេចឹងទៅហើយយើងគឺយើងនៅតែភូមិរបស់យើងចឹងហាសបាទពីព្រោះអីកាល់នឹងយើងមានតែសាលារៀនមួយចឹងទៅគឺយើងទៅរៀនទាំងអស់គ្នាចឹងហាសបាទ៕

កៈ
បាទហើយចឹងនៅពេលដែលលោកពូបានរៀននឹងថាតើសាលារៀនមួយនឹងគឺមានឈ្មោះអ្វីដែលទៅលោកពូចឹងលោកនៅចាំដែលរឺទេលោកពូ???

ខៈ
បាទនិយាយទៅកាល់ដែលខ្ញុំនឹងបានរៀននឹងគឺខ្ញុំនឹងរៀននឹងគឺគ្មានឈ្មោះនោះទេបាទនិយាយទៅគឺជាសាលារៀនគ្មានឈ្មោះតែម្តងហាសបាទហើយយើងនឹងគឺយើងរៀននៅក្រោមផ្ទះនោះទេបាទ៕

កៈ
បាទហើយចឹងនៅពេលដែលគេបានរៀននៅខាងក្រោមផ្ទះនឹងថាតើគេរៀនយ៉ាងមិចដែលទៅលោកពូ???

ខៈ
បាទនៅពេលដែលគែបានរៀននៅខាងក្រោមផ្ទះនឹងគឺផ្ទះរបស់គេនឹងគឺវាមានរាងខ្ពស់ហើយគេបានដាក់ក្តារខៀនអីចឹងទៅហាសបាទបាទចឹងហើយបានគេបានដាក់ឈ្មោះថាសាលារៀនអត់មានឈ្មោះនោះទេបាទបាទហើយនៅពេលដែលខ្ញុំនឹងបានចេញពីសាលារៀនចឹងទៅគឺខ្ញុំនឹងទៅធ្វើការងារអីចឹងទៅ៕

កៈ
បាទហើងចឹងគឺគេបានដាក់ឈ្មោះនឹងថាសាលារៀនអត់មានឈ្មោះបាទហើយចឹងអត់អីទេលោកពូហើយចឹងសំណួរដែលខ្ញុំនឹងចង់សួរលោកពូបន្ថែមថាតើនៅពេលដែលលោកពូបាននៅក្នុងជំនាន់ពោលពតនឹងថាតើលោកពូជួបបញ្ហាលំបាក់អ្វីខ្លះដែលទៅលោកពូ???

ខៈ
បាទប្រសិនជាខ្ញុំនឹងនិយាយពីកាល់ដែលនៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងដូចជាមិនជាសូវមានបញ្ហាលំបាក់អ្វីនោះទេបាទពីព្រោះអីនឹងគេបានអោយខ្ញុំនឹងទៅនៅខាងផ្នែកដឹកជញ្ជូលចឹងហាសបាទហើយនៅពេលដែលគេបានអោយនឹងគឺខាងដឹកជញ្ជូននឹងគឺគេបានអោយរទេះយើងនឹងចំនួន១បាទសំរាប់ដាក់បាយដាក់អីចឹងហាសបាទបាទហើយសំរាប់មួយសប្តាហ៍អីចឹងទៅគឺយើងដឹកនុំហើយនឹងបង្អែមអោយគេម្តងអីចឹងទៅហាសបាទហើយសំរាប់បាយនឹងគឺយើងដឹកអោយគេរាល់ថ្ងៃអីចឹងទៅបាទដូចថាខ្ញុំនឹងគឺមិនបានទៅហ្វឹតហាត់ទៅកាប់ដីអីនឹងគេនោះទេបាទ៕

កៈ
បាទហើយចឹងកាល់ដែលនៅក្នុងជំនាន់ពោលពតនឹងថាតើលោកពូមានអាយុប៉ុន្មានឆ្នាំហើយលោកពូ???

ខៈ
បាទកាល់ដែលនៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងបានអាយុប្រហែលជា១៣ឆ្នាំរឺក៏១៤ឆ្នាំអីចឹងទៅហាសបាទប្រហែលជា១៣ឆ្នាំរឺក៏១៤ឆ្នាំអី៕

កៈ
បាទហើយចឹងនៅពេលដែលលោកពូនៅក្នុងជំនាន់នឹងមានអាយុប្រហែលជា១៣ឆ្នាំរឺក៏១៤ឆ្នាំអីថាតើលោកពូមានដែលបានជួបបញ្ហាដែលគេត្រូវបានបាញ់សំលាប់អីដែលទេលោកពូលោកពូមានដែលបានជួបបញ្ហានឹងដែលរឺទេ???

ខៈបាទនិយាយទៅគឺខ្ញុំនឹងមិនដែលបានជួបបញ្ហានោះទេក៏ប៉ុនតែសំរាប់នៅក្នុងជំនាន់នឹងគឺគេមានវាមានមែនក៏ប៉ុនតែដូចថាគេបានជំលាសគេយើងចេញមកពីពោធិ៍សាត់ហើយនឹងបាត់ដំបងនឹងហាសបាទដែលនៅខាងព្រៃវែងចឹងហាសបាទគឺគេបាននិយាយទៅហាសបាទគឺគេបានយកមកសំលាប់នៅទីកន្លែងនឹងបាទនៅខាងព្រៃវែងនឹងបាទហើយប្រសិនជាយកទៅសំលាប់ដែលនៅខាងនឹងគឺគ្មាននោះទេបាទបាទហើយនិយាយទៅគឺវាតាមស្រុកនោះទេបាទហើយសំរាប់ស្រុកបាភ្នំនឹងគឺវាមែនគឺគេមានសំលាប់ដែលចឹងហាសក៏ប៉ុនតែនឹងក៏គេមិនបានអោយយើងទៅបានទៅជិតហើយនឹងទៅឃើញដែលចឹងហាសបាទគ្រាន់តែយើងនឹងបានលឺគេនិយាយចឹងហាសបាទ៕

ក៖
បាទហើយចឹងលោកពូអត់ដែលបានជួបនឹងបញ្ហាដែលមានភាពលំបាក់អីតឹអត់មានទេមែនដែលទេលោកពូ???

ខ៖
បាទសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងមិនជាសូវបានជួបនឹងបញ្ហាលំបាក់អីច្រើននោះទេបាទនិយាយទាំងឆ្លួតភូមិឆ្លួតអីនឹងគឺខ្ញុំនឹងមិនដែលបានជួបនោះទេបាទ៕

ក៖
បាទចឹងនៅក្នុងជំនាន់ពោលពតនឹងលោកពូមិនជាសូវជួបនឹងបញ្ហាលំបាក់អ្វីនោះទេមែនដែលទេលោកពូបាទហើយចឹងនៅពេលដែលគេបានផ្តល់អោយការងារអោយទៅលោកពូនឹងគឺផ្នែកដឹកជញ្ជូននឹងថាតើគេបានអោយលោកពូនឹងដឹកអីវ៉ាន់អ្វីខ្លះដែលទៅលោកពូ???

ខ៖
បាទនិយាយទៅគឺគេបានអោយយើងនឹងទៅដឹកបាយហើយនឹងសំលរអីចឹងទៅហាសបាទបាយហើយនឹងសំលរគេបានអោយយើងនឹងទៅដឹកអោយគេចឹងទៅរាល់រាល់ថ្ងៃចឹងទៅបាទរហូតដល់មកគេក៏បានអោយយើងនឹងដឹកនុំអោយគេចឹងទៅបាទនៅពេលដែលយើងដឹកនឹងគឺយើងដឹកទៅដល់ព្រៃក្របៅចឹងទៅហាសហើយគេបានអោយរទេះនឹងទៅដឹកចឹងទៅហើយសំរាប់កាល់គេអោយយើងដឹកអំបិលចឹងទៅ៕

ក៖
បាទហើយចឹងគេបានអោយលោកពូដឹកអំបិលនឹងពីណាទៅដល់ណាដែលទៅលោកពូ???

ខ៖
បាទសំរាប់អំបិលនឹងគឺគេបានអោយខ្ញុំនឹងដឹកទៅដល់ព្រៃក្រតួចឡើងទៅដល់ស្វាយអន្ទរបាទហើយបានគេបានចែកចាយនៅស្វាយអន្ទរនឹងតាមប្រជាជនចឹងទៅ៕

ក៖
បាទចឹងនៅពេលដែលលោកពូបានដើលចែកចឹងថាតើគេបានអោយលោកពូបានហូបឆ្អែតដែលរឺទេលោកពូ???

ខ៖
បាទនិយាយទៅគឺអត់អីនោះទេគឺគេបានអោយខ្ញុំនឹងបានហូបគ្រាប់គ្រាន់ដែលតាបាទគឺអត់អីនោះទេនឹងសំរាប់ផ្នែកដឹកជញ្ជូនហាសបាទប៉ុន្មានសំរាប់អ្នកដែលធ្វើស្រែនឹងហាសបាទបាយស្រូវពេញផ្ទះនឹងគឺវាមិនបានអោយប្រជាជននឹងបានស៊ីនោះទេបាទហើយនៅពេលដែលខ្ញុំនឹងបានដឹកអង្ករហើយខ្ញុំនឹងបានដាក់អោយគេចឹងទៅហាសហើយសំរាប់ខ្ញុំនឹងក៏បានហូបឆ្អែតដែលទៅបាទ៕

ក៖
បាទហើយចឹងនៅក្នុងជំនាន់នឹងថាតើលោកពូរាបជួបជុំគ្នាជាមួយនឹងគ្រួសាររបស់លោកពូដែលរឺទេលោកពូ???

ខ៖ បាទនៅក្នុងជំនាន់ពោលពតនឹងគឺនៅក្នុងឆ្នាំ ១៩៧៦ រឺក៏១៩៧៧ នឹងខ្ញុំនឹងក៏បានគ្រួសារចឹងទៅបានបាទហើយនៅពេលដែលខ្ញុំនឹងមានគ្រួសារនឹងនៅពេលនឹងគឺគេបានអោយរៀបអាពាពិហ៍ពិពាពិហ៍គឺគេមានលោកដែលចឹងហាក៏ប៉ុនតែគឺគេមិនបានអោយយើងនឹងយកលោកមកនោះទេបាទគឺគេមិនបាននោះទេហើយចឹងទៅគឺយើងស្រលាញតាមការស្មាក់ចិត្តតាមអ្វីដែលយើងស្រលលញ់របស់យើងចឹងទៅហាសហើយនៅពេលដែលយើងបានរៀបអាពាពិហ៍ពិពាពិហ៍នឹងគឺយើងបានរៀបការបានតែមួយគូរនោះទេហើយបានក្រោយក្រោយទៀតនឹងគឺគេរៀបអាពាពិហ៍ពិពាពិហ៍នឹង១០គូរទៅ២០គូរចឹងទៅបាទបាទហើយនៅក្នុងជំនាន់ខ្ញុំនឹងគឺគេរៀបអាពាពិហ៍ពិពាពិហ៍នឹងបានតែ១គូរហើយយើងមានលោកក៏ប៉ុនតែនឹងគឺគេមិនបានអោយយើងនឹងយកមកនោះទេបាទដល់ពេលក្រោយក្រោយទៀតនឹងគឺគេរៀបអាពាពិហ៍ពិពាពិហ៍នឹងពី៥គូឡើងចឹងទៅបាទនិយាយទៅក្រោយក្រោយទៀតនឹងគឺគេរៀបអាពាពិហ៍ពិពាពិហ៍នឹង៥គូររឺក៏៦ឡើងចឹងរហូតដល់២០គូចឹងហាសបាទ៕

ក៖
បាទហើយចឹងនៅពេលដែលគេបានក្រោយក្រោយទៀតនឹងគឺគេរៀបអាពាពិហ៍ពិពាពិហ៍នឹង២០គូរនឹងថាតើគេរៀបអាពាពិហ៍ពិពាពិហ៍នឹងយ៉ាងមិចដែលទៅលោកពូលោកពូអាចប្រាប់ខ្ញុំនឹងបានដែលរឺទេលោកពូ???

ខ៖
បាទនៅពេលដែលគេរៀបអាពាពិហ៍ពិពាពិហ៍នឹង២០គូនឹងគឺគេមានរោងអីចឹងទៅបាទហើយនៅពេលដែលយើងបានរៀបអាពាពិហ៍ពិពាពិហ៍នឹង២០គូនឹងគឺគេអោយយើងនឹងអង្គុយលើកៅអីចឹងទៅជាជួរចឹងទៅបាទដូចថាគូមួយណាដែលគូរនឹងគ្នាចឹងទៅគឺគេបានអោយគូរនឹងអង្គុយទល់មុខគ្នាចឹងទៅហាសបាទហើយគេអង្គុយលើកៅអីចឹងទៅរហូតហើយពេលដែលគេបានអោយយើងនឹងបានឡើងទៅលើនឹងនិយាយប្តេជ្ញាម្តងម្នាក់ចឹងទៅហាសបាទដូចថានៅពេលដែលគូរទីមួយនឹងបានឡើងទៅមុនចឹងទៅគឺប្តីនឹងឡើងទៅប្តេជ្ញាម្តងចឹងទៅបាទហើយនៅពេលដែលគេបានឡើងទៅប្តេជ្ញាហើយចឹងទៅគឺគេបានអោយមកអង្គុយវិញចឹងទៅប្តេជ្ញារហូតដល់តែគ្រាប់គ្នារហូតដល់ល្ងាចចឹងទៅហើយមេឃុំនឹងគេបានណែនាំចឹងទៅគឺជាមេសហាករនឹងគេបានណែននាំហើយក៏នាំគ្នាចូលឡានចឹងក៏បានគ្នាចាប់ពីនឹងមកចឹងទៅហាសបាទនិយាយទៅគឺគ្មានអ្វីដែលពិបាក់នោះទេហើយប្រសិនជាម្តាយក្មេកហើយនឹងកូនប្រសារនឹងគឺគេមិនដែលបានស្គាល់គ្នានោះទេបាទគឺគ្មានស្គាល់គ្នានោះទេបាទកុំច្រឡំអីណាម្តាយក្មេកហើយនឹងកូនប្រសារនឹងគឺគេមិនដែលបានស្គាល់គ្នានោះទេបាទ៕

ក៖
បាទហើយចឹងនៅពេលដែលគេរៀបអាពាពិហ៏ពិពាពិហ៏នឹងគឺគេមិនបានអោយឪពុកហើយនឹងម្ដាយនឹងបានចូលរួមទេមែនដែលទេលោកពូ???

ខ៖
បាទនិយាយទៅគឺគេមិនបានអោយឪពុកហើយនឹងម្ដាយនឹងបានចូលរួមទេបាទគឺគ្មាននោះទេនិយាយទៅគឺមានតែសម័យខ្លួននឹងនោះទេបានចឹងហើយបានខ្ញុំនឹងបាននិយាយថាកូនប្រសារមួយណាមួយណាគឺគ្មានដឹងនោះទេពីព្រោះអីនឹងគឺគេមិនបានអោយឪពុកហើយនឹងម្ដាយនឹងបានចូលរួមផងនឹង៕

ក៖
បាទចឹងពិបាក់ដែលនឹងលោកពូបាទហើយចឹងនៅពេលដែលគេបានរៀបអាពាពិហ៏ពិពាពិហ៏ហើយចឹងគេអត់អោយឪពុកហើយនឹងម្ដាយបានចូលរួមនឹងរៀបអាពាពិហ៏ពិពាពិហ៏ចឹងនៅពេលដែលរៀបអាពាពិហ៏ពិពាពិហ៏ហើយចឹងថាតើយើងអាចនាំកូនប្រសាររបស់គាត់នឹងទៅលេងម្ដាយហើយនឹងឪពុកក្មេកនឹងបានដែលរឺទេលោកពូ???

ខ៖
បាទនៅពេលដែលគេបានរៀបអាពាពិហ៏ពិពាពិហ៏ហើយចឹងគេអាចនាំមកលេងម្ដាយហើយនឹងឪពុកក្មេកនឹងបានបាទហើយគេក៏បានជួបគ្នាចឹងទៅហើយនិយាយគ្នាលេងចឹងទៅបាទ៕

ក៖
បាទហើយចឹងនៅពេលដែលលោកពូបានរៀបអាពាពិហ៏ពិពាពិហ៏ហើយចឹងថាតើលោកពូមានអារម្មណ៏យ៉ាងមិចដែលទៅលោកពូ???

ខ៖
បាទនិយាយទៅគឺគ្មានអារម្មណ៏អ្វីនោះទេបាទពីព្រោះអីនៅពេលដែលយើងបានរៀបអាពាពិហ៏ពិពាពិហ៏បានមួយថ្ងៃរឺក៏២ថ្ងៃអីចឹងទៅគេក៏បានបំបែកគ្នាទៀតចឹងទៅជួនកាល់នឹងគេបានអោយយើងទៅជាមួយនឹងគ្នាចឹងហើយពេលខ្លះនឹងក៏គេបានបំបែកយើងចឹងទៅបាទហើយនៅពេលដែលយើងបានបែកគ្នាចឹងទៅខាងស្រីនឹងគឺគេធ្វើការងារខាងស្រីចឹងទៅហើយសំរាប់ខាងប្រុសនឹងគឺគេបានធ្វើការងារខាងប្រុសចឹងទៅហើយរហូតធ្វើការងារចប់ចឹងទៅគឺគេបានអោយយើងនឹងបានជួបគ្នាវិញចឹងទៅបាទហើយនៅពេលដែលមានពេលខ្លះនឹងប្រសិនជាយើងធ្វើការងារខាងឆ្ងាយអីចឹងគឺគេបានអោយយើងទៅធ្វើការងារទាំងប្ដីទាំងប្រពន្ធចឹងទៅបាទជួលកាល់នឹងគឺយើងដេកនៅនឹងទៅបាទ៕

ក៖
បាទហើយចឹងខ្ញុំចង់សួរទៅកាន់លោកពូមួយទៀតថាតើលោកមានបានដឹងទេថានៅក្នុងជំ

នាន់សពោលពតនឹងថាតើនៅឆ្នាំណាដែលគេបានជួយរំដោះប្រជាជននៅក្នុងជំនាន់ពោលពតហាសលោកពូ???

ខ៖ បាទនៅពេលដែលគេបានមកជួយរំដោះយើងនឹងគឺនៅក្នុងឆ្នាំ ១៩៧៩ ៕

ក៖
បាទហើយចឹងនៅពេលដែលគេបានមកជួយរំដោះយើងនឹងថាតើគេបានមកជួយរំដោះយើងនឹងយ៉ាងមិចដែលទៅលោកពូ???

ខ៖ បាទសំរាប់នៅក្នុងឆ្នាំ ១៩៧៩
នឹងគឺខ្ញុំនឹងបានឃើញទាហ៊ានដែលបានមកពីខាងកើតនឹងវាច្រើនពេកចឹងហាសបាទហើយនៅពេលដែលខ្ញុំនឹងបានឃើញទាហ៊ានដែលបាក់នឹងគឺខ្ញុំនឹងមិនបានដឹងថាទាហ៊ាននឹងខាងណាខាងណាគឺខ្ញុំនឹងមិនបានដឹងនោះទេបាទនិយាយទៅគឺសុទ្ធតែមានរទេះគោហើយនឹងរទេះសេះហើយនឹងរទេះផ្សេងផ្សេងដែលដឹកកាប់ភ្លើងនឹងមកខ្លះនឹងក៏បានដើរមករញ៉ៀវរញ៉ៀពេញតែព្រៃនឹងតែម្តងចឹងហាសបាទដល់ហើយចឹងទៅខ្ញុំនឹងក៏បានលឺសូរគ្រាប់កាំភ្លើងបាទគឺខ្ញុំនឹងក៏បានលឺសូរគ្រាប់កាំភ្លើងខាងស្វាយរៀងបាទសំរាប់រាល់ខាងខាងស្វាយរៀងរបស់ខ្ញុំនឹងវាមិនដឹងជាយ៉ាងមិចនោះទេបាទដល់ពេលបានតែបន្តិចមកនឹងក៏លឺដល់ខាងកំពុងចាមវិញម្តងវិងចឹងទៅដល់ពេលទៀតចឹងទៅគេបានអោយខ្ញុំនឹងជំលាសមកដល់ភ្នំចារកាច់ដែលខាងប្រុសប្រុសនឹងហាសបាទគេបើលកាំភ្លើងអីនឹងយកទៅសំលាប់ហើយគេអោយយើងនឹងសំលាប់យួនខ្លាចយួននឹងមកវានឹងវះពោះនឹងជ្រកខ្មៅហើយបាទដល់ហើយចឹងទៅក៏មានខាងមិនដឹងជាខាងណាទេក៏ប៉ុនតែយើងអាចថាបានគេជាអ្នកធ្វើការងារចឹងទៅហើយគេបានជិះម៉ូតូនឹងមួយគ្រឿងនឹងបានចូលមកដល់ភូមិរបស់ខ្ញុំនឹងហើយក៏បានជួបខ្ញុំនឹងវត្តហើយគេក៏បានសួរយើងថាបងបងឯងទៅណាវិញហើយពេលនឹងគឺខ្ញុំនឹងបាននិយាយទៅគាន់គាត់វិញដែលថាគឺខ្ញុំនឹងទៅប្រមូលប្រជាជនរបស់ខ្ញុំនឹងទៅខាងលិចនិយាយពីរបស់គាត់នឹងហាសហើយពេលនឹងគេនឹងបាននិយាយថាបងអើយបងកុំទៅប្រមូលប្រជាជនអីហើយគេបានអោយខ្ញុំនឹងមកខាងកើតវិញមកចឹងហាសបាទហើយកុំទៅជឿរខាងខុសស្មារបស់គេនឹងថាយួនវះពោះជ្រកដាក់ខ្មៅអីពីណាចឹងទៅហើយក៏ខ្ញុំនឹងបានទៅប្រមូលប្រជាជននឹងទៅខាងនេះចឹងទៅដែលពួកវានៅភូមិរបស់ខ្ញុំនឹងហើយវានៅកំពុងនឹងវាលនៅនឹងហាសបាទគឺវាមិនទាន់បានចេញទៅណានោះទេគ្រាន់តែពួកវានឹងបានចេញភូមិរបស់យើងចឹងហាសបាទហើយពួកវានឹងបានទៅរស់នៅឯវាល់ឯនោះពីព្រោះអីនឹងទាហ៊ាននឹងវាបានបាក់មកច្រើនពេកហាសហើយពួកនឹងក៏បានទៅវាល់ហើយនឹងដឹកនឹងវាល់ហើយក៏ស៊ីចុចអីនឹងគឺនៅឯតែវាំល់នឹងឯហាសបាទទាំងប្រធានមេកងហើយនឹងទាំងប្រធានសហកររបស់គេនឹងគេបាននិយាយថាមានមនុស្សនឹងជិះម៉ូតូចំនួននឹង២នាក់ហើយគេនឹងមិនអោយនិយាយថាអោយយើងទៅលិចហើយអោយយើងបត់ទៅខាងក្រោយវិញទៅចឹងហាសបាទក៏ប៉ុនតែមិនដឹងជាទាហ៊ានខាងណានោះទេយើងមិនបានដឹងនោះបាទហើយគេគ្រាន់តែប្រាប់យើងតែប៉ុននឹងគេក៏បានឡើងម៉ូតូឡើងទៅបាត់ចឹងទៅបាទហើយយើងចេះតែតាមប្រជាជនយើ

ងចឹងទៅហាសបាទហើយសំរាប់ពួកពោលពតនឹងគឺពួកវាបានអោយពួកប្រុសប្រុសនឹងឡើងទៅលើភ្នំឈើកាច់ដើម្បីទៅរើសកាំភ្លើងក៏ប៉ុនតែធាតុពិតរបស់គេនឹងគេប្រមូលប្រុសប្រុសនឹងគេយកទៅវៃចោលនោះទេបាទហើយគឺគេមិនបានបើកកាំភ្លើងនឹងអោយយើងនោះទេបាទ៕

កៈ

បាទហើយចឹងនៅពេលដែលយើងបានដឹកពីកំពោងរបស់គេដែលគេនឹងយកយើងនឹងទៅវៃចោលតែម្តងមែនដែលទេលោកពូ???

ខៈ

បាទនិយាយទៅគឺយើងបានដឹងកំពោងរបស់គេទុកជាមុនចឹងហាសហើយសំរាប់យើងទាំងអស់គ្នានឹងក៏បានប៉ាក់ទុកម្មហើយមុនដែលទាហ៊ានមុនដែលគេបានមកពីខាងកើតនឹងហាសហើយសំរាប់ឆ្នាំ ១៩៧៩
នឹងគឺខាងប៉ាក់ទុកម្មមុននឹងហើយសំរាប់ខ្ញុំនឹងគឺខ្ញុំបានរត់ជិតទៅដល់ស្រុកយួនដែលតែខ្ញុំនឹងរត់ចូលទៅមិនបានរួចចឹងទៅក៏ខ្ញុំនឹងបានប្រាស់វិញមក៕

កៈ

បាទហើយចឹងនៅពេលដែលលោកពូបានរត់ត្រឡប់មកវិញចឹងថាតើពួកទាហ៊ាននឹងគេមានបានធ្វើបាប់លោកពូដែលរឺទេលោកពូ???

ខៈ

បាទនៅពេលដែលខ្ញុំនឹងបានរត់ត្រឡប់មកវិញចឹងទៅគឺគ្មាននាក់ធ្វើបាប់ខ្ញុំនឹងនោះទេគ្រាន់តែវារាងប្លែកចឹងហាសបាទប្លែកត្រង់ថានៅពេលដែលខ្ញុំនឹងបានរត់បានមកដល់នឹងគឺខ្ញុំនឹងបានទៅដេកចំនួន៥យប់ហើយរហូតខ្ញុំនឹងបានមកដល់ផ្ទះវិញចឹងហើយពេលដែលបានមកដល់នឹងគឺមេប្រធានសហករនឹងគេបាននិយាយថាប្រាប់យើងថានៅពេលដែលគេសួរយើងត្រូវតែនិយាយថាយើងមកពីធ្វើមោងធ្វើអោយបងប្អូននឹងដែលពួកគាត់ទើបតែមកពីខេត្តពោធិ៍សាត់បាទហើយប្រសិនជាគេបានសួរយើងយើងត្រូវតែឆ្លើយជាគេចឹងទៅបាទហើយដល់ពេលដែលខ្ញុំនឹងបានមកដល់ផ្ទះម្តាយរបស់ខ្ញុំនឹងមានទាហ៊ាននឹងមានចំនួន២នាក់គឺគេបានចូលទៅធ្វើខ្វិតទុំហើយពេលនឹងម្តាយរបស់ខ្ញុំនឹងគាត់ចេះតែសួរទៅកាន់ខ្ញុំនឹងថាកូនឯងទើបតែមកពីណាចឹងហាសហើយខ្ញុំនឹងក៏បាននិយាយទៅកាន់គាត់វិញថាខ្វិតទុំនឹងវាមានជ្រុះទៀតដែលរឺទេហើយខ្ញុំនឹងចេះតែសួរបន្លំគាត់ចឹងហាសពីព្រោះអីនឹងគឺខ្ញុំនឹងមិនចង់អោយគាត់នឹងបានសួរខ្ញុំនឹងនោះទេបាទហើយសំរាប់ទាហ៊ាននឹងក៏វាមិនបានចាប់អារម្មណ៍ថាយើងនឹងមកពីពីណាអីចឹងហាសដែលបាទដល់ហើយចឹងម្តាយរបស់ខ្ញុំនឹងគឺគាត់បានសួរខ្ញុំនឹងច្រើនពេកខ្ញុំនឹងក៏បានសឹបប្រាប់គាត់ថាកុំទាន់អាសួរខ្ញុំម៉ែមានគេនឹងបានតាមខ្ញុំនឹងពីក្រោយចឹងហាសដល់ហើយចឹងទៅខ្ញុំនឹងក៏បានដើរទៅផ្ទះរបស់ខ្ញុំទៀតហើយនៅពេលដែលខ្ញុំនឹងបានដើលទៅចឹងទៅគឺពួកពោលពតនឹងគឺតាមខ្ញុំនឹងរហូតហើយនៅពេលដែលគេបានតាមខ្ញុំនឹងគឺខ្ញុំមិនបានដឹងថាប្រពន្ធរបស់ខ្ញុំនឹងគាត់បានមកដេកនៅផ្ទះរបស់ខ្ញុំដែលចឹង

ហាសហើយសំរាប់ខ្ញុំស្មាន់តែគេនឹងនៅផ្ទះរបស់ឪពុករបស់គេចឹងហាសហើយសំរាប់ខ្ញុំនឹង គឺខ្ញុំនឹងចេះតែហូសទៅហូសទៅក៏បានជួបទាហ៊ានរបស់ពួកពោលពតនឹងមានចំនួន២នាក់ទៀតហើយនៅពេលដែលខ្ញុំនឹងបានជួបពួកពោលពតនឹងគឺពួកវាបានផ្ទុងកាំភ្លើងមកដាក់យើង៤ដើមទៀតហើយគេដើលតាមពីក្រោយខ្ញុំនឹងរហូតហើយគេក៏បាននិយាយមកកាន់ខ្ញុំថាចុះវាយ៉ាងមិចបានជាដើលចូលផ្ទះហើយមិចក៏ដើលចេញទៅវិញយ៉ាងចឹងហើយនៅពេលនឹងគឺខ្ញុំនឹងបាននិយាយទៅកាន់ពួកពោលពតនឹងវិញថាខ្ញុំនឹងបានមកនឹងគឺខ្ញុំនឹងមករកថ្នាំឪពុកក្មេកទុក្ខសំរាប់ហូបនិយាយទៅគឺជា(បារី)ហាសនឹងគឺជាថ្នាំហើយចឹងទៅគឺខ្ញុំនឹងក៏បាននិយាយកហុកគេហើយខ្ញុំក៏បាននិយាយទៅវិញដែលថាចុះបងឯងនឹងទៅណាវិញហើយខ្ញុំនឹងក៏បាននិយាយថាគឺខ្ញុំនឹងត្រប់ទៅផ្ទះវិញហើយពួកពោលពតបាននិយាយថាផ្ទះរបស់ឯងនឹងនៅទីកន្លែងណាហើយពេលនឹងខ្ញុំក៏បាននិយាយទៅវញថាផ្ទះរបស់ខ្ញុំនឹងគឺនៅខាងក្រោយនឹងនោះទេបាទហើយពេលនឹងគឺមានពួកពោលពតនឹងមកទៀតនិយាយទៅគឺជួបរហូតដល់ខ្ញុំនឹងទៅដេកបាទពួកវានឹងបានត្រឡប់ទៅវិញក៏ប៉ុនតែនឹងគឺពួកវានឹងមិនបានធ្វើបាប់យើងនោះទេបាទគឺពួកវាមិនបានវៃយើងនឹងធ្វើបាប់យើងទេគ្រាន់តែពួកវានឹងបានផ្ទុងកាំភ្លើងមកយើងចឹងហាសបាទ៕

កៈ
បាទហើយចឹងនៅពេលដែលលោកពូដែលបានរស់នៅក្នុងជំនាន់នឹងលោកពូអត់សូវមានភាពលំបាក់អ្វីនោះទេមែនដែលទេលោកហើយនៅពេលដែលនៅក្នុងជំនាន់នឹងគឺគេបានជួយរំដោះដែលនៅក្នុងឆ្នាំ ១៩៧៩
នឹងហើយសំរាប់លោកពូនៅពេលដែលគេបានបែកជំនាន់ពោលពតនឹងថាតើលោកពូបានទៅរស់នៅទីកន្លែងណាដែលទៅលោកពូអាចប្រាប់បានដែលរឺទេលោកពូ???

ខៈ
បាទនៅពេលដែលខ្ញុំនឹងបានបែកពីជំនាន់ពោលពតនឹងគឺខ្ញុំនឹងបានមកបត់ចូលមកកាន់ភូមិរបស់ខ្ញុំនឹងវិញនិយាយទៅគឺទាំងអស់គ្នាទាំងមួយភូមិនឹងតែម្តងហាសគឺគេបានទៅរស់នៅវាល់ទាំងអស់ហើយដល់ពេលចឹងដល់ពេលដែលយើងបាត់ផុសចឹងទៅហាសបាទហើយនៅពេលដែលគេបានបាក់ពទ័ផុសចឹងទៅយើងទាំងអស់គ្នានឹងឡើងមកតាមភូមិវិញចឹងមកបាទ៕

កៈ
បាទហើយចឹងថាតើលោកពូបានត្រឡប់មករស់នៅស្រុកនឹងគឺជាខេត្តព្រៃវែងនឹងមែនដែលទេលោកពូ???

ខៈ
បាទនៅពេលដែលបានបែកនឹងគឺគេបានជូនយើងនឹងទៅតាមភូមិរបស់យើងវិញអីចឹងទៅហាសបាទគឺជូនយើងតាមធម្មតាចឹងទៅបាទ៕

កៈ
បាទហើយចឹងពេលដែលលោកពូបានរត់ចូលទៅក្នុងជំនាន់នឹងថាតើលោកពូមានជួបបញ្ហាដែលលំបាក់នៅក្នុងជំនាន់ពោលពតនឹងដែលរឺទេលោកពូ???

ខៈ
បាទនិយាយទៅគឺលំបាក់ដែលនៅពេលដែលយើងរត់នឹងគឺយើងបានជួបនឹងពួកពោលពតនឹងយើងចឹងទៅយើងមានអារម្មណ៍ថាភ័យក៏ប៉ុនតែគេមិនបានបាញ់យើងចឹងហាសហើយនៅពេលដែលយើងរត់នឹងគឺរត់មិនបានដឹងភូមស្រាស្តហើយយើងបាននិយាយថាយើងមិនបានរត់នោះទេគឺយើរត់ចូលទៅហូបបាយនោះទេហើយនៅពេលដែលរត់ពីរោងបាយរបស់គេនឹងហើយក៏រត់ចូលទៅកាន់រោងសន្តិសុខរបស់គេដូចថាគេជាអ្នកយាមគុកចឹងហាសពីព្រោះអីយើងមិនបានដឹងថាវាឆ្ងាយបាទហើយនៅពេលដែលយើងបានចូលទៅគឺគេមិនបានថាអីអោយយើងនោះទេគ្រាន់តែគេបានសួរយើងថាយើងនឹងគឺជាអ្នកណាគេចឹងហាសបាទហើយយើងនឹងមកពីណាហើយយើងក៏ប្រាប់គេតាមនឹងទៅហើយគេអោយយើងនឹងបានហូបបាយចឹងទៅដល់មានពេលមួយនឹងគឺខ្ញុំនឹងបានរត់ចូលទៅកាន់ព្រៃនឹងគឺខ្ញុំនឹងបានជួបអ្នកដែលបានដាក់មោងអីនឹងនៅក្នុងព្រៃនឹងទៀតហើយអ្នកដែលបានសួរយើងនឹងថាមកពីណាពីណានឹងហើយពេលនឹងគឺយើងមិនបានឆ្លើយអ្វីជាមួយនឹងគេនោះទេបាទនិយាយទៅគឺរត់តែម្តងហើយនៅពេលដែលយើងរត់នឹងគឺរត់កាត់ទឹកលឺសូរប្រូងប្រូងប្រូងខ្វែងទាំងអស់គ្នានឹងបាទហើយនៅពេលដែលដល់ពេលយប់ចឹងម៉ោងប្រហែល៩យប់នឹងទៅគឺខ្ញុំនឹងបានទៅលួចកាត់ស្រូវបានប្រហែលជាបិននឹងស្រូវហាសបាទហើយនៅពេលដែលបានស្រូវនឹងហើយចឹងទៅគឺខ្ញុំនឹងបានចែកស្រូវនឹងបានក្នុងម្នាក់បានមួយដៃមួយដៃហើយយើងក៏បានទំពាហើយនឹងជញ្ជុកទំពាហើយនឹងជញ្ជុកចឹងទៅពីព្រោះអីយើងអត់មានបាយនោះទេបាទ៕

កៈ
បាទហើយចឹងលលោកពូអត់បានយកស្រូវនឹងទៅបុកសិនអោយវាក្លាយទៅជាបាយសិនទៅលោកពូ???

ខៈ
បាទនិយាយទៅគឺអត់ទេយើងបានទៅរត់ហើយនឹងទៅកាត់ស្រូវដែលវាបែកមានទឹកដោះតិចតិចយើងយកមកទំពាហើយនឹងជញ្ជុកទំពាហើយនឹងជញ្ជុកចឹងទៅបាទ៕

កៈ
បាទហើយចឹងនៅពេលដែលលោកពូបានរើសស្រូវនឹងយកមកនឹងថាតើលោកពូបានហូបឆ្អែតដែករឺទេលោកពូ???

ខៈ
បាទប្រសិនជានិយាយទៅគឺមិនបានឆ្អែកនោះទេពីព្រោះអីយើងនឹងគ្រាន់តែបានទំពាហើយនឹងជញ្ជុកនោះទេបាទហើយសំរាប់បាយក្រៀបនឹងដែលយើងបានយកបាយនឹងទៅពីផ្ទះនឹ

ងប្រហែលជាបានមួយកំបង់តែប៉ុននឹងបាទហើយសំរាប់បាយក្រៀបនឹងគឺយើងមិនហ៊ានស៊ី
នោះទេគឺយើងទុក្ខបាទហើយយើងចេះតែទុក្ខវាទៅហើយយើងទាំងអស់គ្នាសុខចិត្តដើរទៅ
កាត់ស្រូវសំរាប់ស៊ីចឹងទៅបាទ៕

កៈ
បាទហើយចឹងនៅពេលដែលលោកពូទុក្ខបាយក្រៀបនឹងថាតើវាមិនបានដុះសិទ្ធទេមែនទេ
លោកពូ???

ខៈ
បាទនិយាយទៅគឺវាវាមិនបានដុះសិទ្ធទេហើយនិយាយទៅប្រសិនជាយើងនឹងទុក្ខមិនបាន
ប្រយ័ត្នទេគេនឹងលួចស៊ីអស់របស់នឹងហាសអ្នកដែលរត់ជាមួយនឹងយើងនឹងហាសបាទចឹង
យើងត្រូវតែរក្សាវាហើយយើងចេះតែលាក់លាក់បាទហើយដូចថានៅពេលដែលយើងបាន
ទៅសុំបាយអ្នកភូមិគេបានអិចឹងបាទនៅពេលដែលយើងបានសុំបាយអ្នកភូមិនឹងគឺគេបាន
យកបាយមកអោយយើងចឹងហាសហើយគេបានវិចបាយយកមកអោយយើងចឹងទៅបាទ
៕

កៈ
បាទហើយចឹងនៅពេលដែលថាតើអ្នកណាដែលដែលបានអោយបាយលោកពូដែលទៅ
លោកពូ???

ខៈ
បាទគឺអ្នកស្រុកភូមិនឹងហាសពីព្រោះអីនឹងគឺយើងបានទៅទាក់ទងនឹងប្រធានសហាកររបស់
គេចឹងហាសបាទដំបូងនឹងយើងបានកហុកគេថាយើងនឹងទៅកាប់ឬស្សីបង់អោនោះទេបាទ
ទៅកាប់ឬស្សីបង់អោនោះទេហើយសំរាប់សំបុត្រនឹងក៏យើងនឹងជាអ្នកសរសេរដោយខ្លួនឯ
ងដែលហើយសំរាប់ស៊ីញ៉េខ្លួនរបស់យើងតែយើងគ្រាន់តែដាក់ឈ្មោះរបស់មេឃុំតែសំរាប់
មេឃុំនឹងគឺគាត់មិនបានដឹងនោះទេបាទហើយសំរាប់មេប្រធានសហាករកនឹងអត់បានដឹងថា
យើងបានខ្លែងបន្លំនោះទេហើយនៅពេលដែលយើងបានចូលទៅដល់នឹងយើងកំពោងរបស់
យើងមិនមែនទៅកាប់ឬស្សីឯងណាគឺយើងរត់ពីបក្សទុកម្មផងហើយនឹងទៅរត់យកកាំភ្លើង
ផងហើយសំរាប់កាំភ្លើងនឹងគឺគេបានកប់ទុក្ខចឹងហាសហើយដល់ពេលចឹងទៅគឺយើងយក
កាំភ្លើងមិនបានពីព្រោះអីពួកវានឹងបានបោះទីតាំងនៅទីកន្លែងនឹងហើយចឹងហាសបាទ៕

កៈ បាទហើយចឹងលោកពូមានចេះបាញ់កាំភ្លើងដែលរឺទេលោកពូសំរាប់ពូហាស???

ខៈ បាទសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងចេះបាញ់កាំភ្លើងតាបាទ៕

កៈ
បាទចឹងបានន័យថាលោកពូចេះបាញ់កាំភ្លើងហើយចឹងនៅក្នុងជំនាន់នឹងហើយសំរាប់លោ

កពូប៉ាក់ទុកម្មហើយលោកពូចេះបាញ់កាំភ្លើងចឹងហើយសំរាប់កាំភ្លើងនឹងវាធ្ងន់ដែលរឺទេលោកពូ???

ខ៖
បាទសំរាប់កាំភ្លើងនឹងគឺវាធ្ងន់ហើយហើយសំរាប់កាំភ្លើងនឹងគឺវាចេះវាមិនមែនសំរាប់ខ្ញុំនឹងមិនជាអ្នកដែលធ្វើជាទាហ៊ាននោះទេហាសសំរាប់បបងប្អូនដែលរស់នៅក្នុងភូមិនឹងគឺគេបានរត់ដែលរត់បាក់ទាហ៊ាននឹងមកនឹងគឺគេបានយកកាំភ្លើងនឹងទៅកប់ហើយរត់មានតែមនុស្សមកចឹងទៅរត់មានតែមនុស្សមកចឹងហើយចឹងគឺគេបានយកកាំភ្លើងនឹងទៅកប់ទៅហើយនៅពេលដែលយើងចង់ទៅរកយកកាំភ្លើងនឹងវិញពួកវានឹងបានបោះទីតាំងទីកន្លែងនឹងតែម្តងហាសបាទ៕

ក៖
បាទហើយចឹងនៅពេលដែលគេបានបោះទីតាំងនៅកន្លែងដែលគេបានកប់កាំភ្លើងនឹងចឹងលោកពូមិនអាចទៅយកកាំភ្លើងបានទេមែនដែលទេលោកពូ???

ខ៖
បាទពេលដែលគេបានបោះទីតាំងនៅកន្លែងដែលគេបានកប់កាំភ្លើងនឹងគឺខ្ញុំនឹងមិនអាចទៅយកកាំភ្លើងបានទេបាទនិយាយទៅគឺយើងចូលមិនបាននោះទេ៕

ក៖
បាទហើយចឹងនៅពេលដែលគេបានបោះទីតាំងនៅកន្លែងដែលគេបានកប់កាំភ្លើងនឹងគឺគេបានដាក់ទីតាំងនឹងនៅកន្លែងណាដែលទៅលោកពូ???

ខ៖
បាទនៅពេលដែលគែបានដាក់ទីតាំងកប់កាំភ្លើងនឹងគឺគេបានដាក់នៅនិយាយទៅគឺនៅក្នុងស្រុកស្វាយអន្ទរដែលក៏ប៉ុនតែនៅឃុំព្រៃជ្រៀងឃុំពាងរោងហាសបាទឃុំពាងរោងឃុំព្រៃជ្រៀងនឹងបាទ៕

ក៖
បាទហើយចឹងនៅពេលដែលលោកពូយកមិនបានចឹងថាតើនៅពេលដែលលោកពូបានត្រឡប់ទៅវិញនឹងថាតើលោកពូបានត្រឡប់ទៅទីកន្លែងណាដែលទៅលោកពូ???

ខ៖
បាទនិយាយនៅពេលដែលខ្ញុំនឹងយកកាំភ្លើងនឹងមិនបានគឺខ្ញុំនឹងបានទៅតាមគេចឹងហាសគឺទៅតាមរយះអ្នកដែលនាំសារដែលគេបានជិះសេះអីនឹងបាទគឺគេបានជិះសេះនឹងទៅដល់ជិតព្រំដែនយួនចឹងហាសហើយអ្នកដែលបានទៅនឹងក៏បានស្លាប់ហើយសំរាប់អ្នកដែលបានជិះសេះនឹងក៏គេបានទៅបាត់ចឹងទៅហើយនៅពេលដែលគេបានបើកកាំភ្លើងនឹងគឺពួកវានឹងដើរតែស្មើជើងហើយនឹងដើរនៅក្នុងតែព្រៃនឹងហាសបាទ៕

កៈ
បាទហើយចឹងនៅពេលដែលលោកពូដើរស្មើជើងនឹងថាតើលោកពូដើរទៅភ្នំពេញរឺក៏លោកពូដើលទៅណាវិញដែលទៅលោកពូ???

ខៈ បាទនៅពេលដែលខ្ញុំនឹងបានដើលនឹងគឺខ្ញុំនឹងបានដើរទៅស្រុកយួននឹងតែម្តងបាទ៕

កៈ បាទហើយចឹងលោកពូមានបានចេះភាសាវៀតណាមដែលរឺទេលោកពូ???

ខៈ
បាទសំរាប់ខ្ញុំនឹងគឺខ្ញុំមិនបានចេះភាសាវៀតណាមនោះទេបាទពីព្រោះអីនឹងនៅពេលដែលខ្ញុំនឹងបានទៅស្រុកយួននឹងគឺខ្ញុំមិនបានទៅតែឯងនោះទេគឺយើងមានគ្នាច្រើនណាស់បាទរួមមានស្រីប្រុសស្រីប្រុសចឹងទៅហាសបាទហើយនៅពេលដែលយើងទៅនឹងគឺយើងទៅដើម្បីអោយគេនឹងជួយយើងនឹងនោះទេបាទ៕

កៈ
បាទហើយចឹងនៅពេលដែលលោកពូមិនបានចេះភាសាវៀតណាមចឹងថាតើលោពូនិយាយជាមួយគេនឹងយ៉ាងមិចទៅលោកពូ???

ខៈ
បាទសំរាប់ខ្ញុំនឹងគឺខ្ញុំមិនដឹងនោះទេហោហោហោហោហោហាចេះតែយោលយោលនឹងគេចឹងទៅបាទ៕

កៈ
បាទហើយចឹងនៅក្នុងឆ្នាំណាដែលទៅដែលលោកពូបានមករស់នៅភ្នំពេញដេលទៅលោកពូ???

ខៈ បាទសំរាប់ខ្ញុំបានមករស់នៅភ្នំពេញនឹងគឺនៅក្នុងឆ្នាំ ១៩៩២ ៕

កៈ បាទហើយចឹងនៅក្នុងឆ្នាំ ១៩៩២
នឹងថាតើលោកពូបានមករស់នៅភ្នំពេញនឹងថាតើលោកពូបានរស់នៅទីកន្លែងណាដែលទៅលោកពូ???

ខៈ បាទនៅក្នុងឆ្នាំ ១៩៩២ នឹង គឺខ្ញុំនឹងរស់នៅទីកន្លែងនឹងតែម្តងបាទ៕

កៈ
បាទហើយចឹងនៅពេលដែលលោកពូបានរត់ពីជំនាន់ពោលពតនឹងលោកពូបានមករស់នៅទីកន្លែងនេះចឹងនៅក្នុងឆ្នាំ ១៩៩២
លោកពូនៅទីកន្លែងនឹងរហូតតែម្តងមែនដែលទេលោកពូបាទហើយចឹងនៅពេលដែលលោ

កពូរស់នៅទីកន្លែងនឹងលោកពូរស់នៅអស់រយៈពេលប៉ុន្មានឆ្នាំហើយលោកពូអាចប្រាប់ខ្ញុំបានដែលទេលោកពូ???

ខ៖ បាទប្រសិនជាយើងគិតទៅតាំងពីឆ្នាំ ១៩៩២ រហូតមកឆ្នាំ ២០១៨ ហើយបាទមិនដឹងជាប៉ុន្មាននោះទេបានតែប្រសិនជាគិតទៅប្រហែលជា ៣០ឆ្នាំទៅ៤០ឆ្នាំហើយចឹងហាសបាទ៕

ក៖

បាទប្រសិនជាគិតទៅប្រហែល៣០ឆ្នាំជាងហើយបាទហើយចឹងអរគុណច្រើនមែនទែនលោកពូខ្ញុំចង់សួរលោកពូមួយទៀតថាតើនៅពេលដែលលោកពូបានមករស់នៅភ្នំពេញនឹងថាតើលោកពូប្រកបមុខរបបអ្វីគេដែលទៅលោកពូ???

ខ៖

បាទនៅពេលដែលយើងបានរស់នៅសព្វថ្ងៃនឹងគឺយើងបានធ្វើការងារខាងសំណង់ចឹងហាសហើយសំរាប់ប្រពន្ធរបស់ខ្ញុំនឹងកាល់នឹងគឺខ្ញុំបានរត់ម៉ូតូឌុបចឹងហាសបាទហើយពេលនឹងគឺយើងបានដាំឈូសហើយនឹងដាំបឹងកំបោកអីចឹងទៅហើយនៅពេលដែលយើងបានទាំងអស់នឹងហើយគឺយើងយកវានឹងទៅលក់ហើយសំរាប់ប្រពន្ធរបស់ខ្ញុំនឹងគឺគេបានបេះស្លឹកឈូសហើយក៏បានយកទៅលក់ចឹងទៅហើយសំរាប់ខ្ញុំនឹងគឺខ្ញុំធ្វើការងារខាងសំណង់នឹងហើយបានក្នុងមួយថ្ងៃនឹងបានតែប្រាក់ ៦០០០រៀល នោះទេបាទ៕

ក៖

បាទហើយនៅពេលដែលលោកពូបានរស់នៅភ្នំពេញនឹងលោកពូធ្វើការងារខាងសំណង់នឹងនៅក្នុងឆ្នាំ ១៩៩២
នឹងបាទហើយចឹងរហូតមកដល់សព្វថ្ងៃនឹងថាតើលោកពូមានបានផ្លាស់ប្តូរមុខរបបអ្វីផ្សេងក្រៅពីសំណង់នឹងដែលរឺទេលោកពូ???

ខ៖

បាទនិយាយទៅគឺខ្ញុំនឹងធ្វើការងារខាសំណង់រហូតមករហូតដល់ពេលដែលខ្ញុំនឹងបានចាស់ទៅនឹងរហូតដល់ខ្ញុំនឹងធ្វើការងារខាងសំណង់នឹងលេងបានចឹងក៏ខ្ញុំនឹងបានឈប់ចឹងទៅហើយសំរាប់កូនរបស់ខ្ញុំនឹងក៏វាបានធំធំអស់ហើយចឹងហាសបាទ៕

ក៖

បាទហើយចឹងសព្វថ្ងៃនឹងលោកពូមិនទាន់បានប្រកបមុខរបបអ្វីនោះទេមែនដែលទេលោកពូ???

ខ៖

បាទសំរាប់សព្វថ្ងៃនឹងគឺខ្ញុំនឹងមិនទាន់បានប្រកមមុខរបបអ្វីនោះទេបាទដូចថាយើងធ្វើការងារលេងបានអីចឹងហាសបាទ៕

កៈ

បាទហើយចឹងខ្ញុំចង់សួរលោកពូមួយទៀតថាតើនៅពេលដែលលោកពូបានរួចផុសពីជីវិតដែលមានភាពលំបាក់ដែលនៅក្នុងជំនាន់ពោលពតនឹងរហូតមកដល់សព្វថ្ងៃនឹងថាតើលោកពូមានបទពិសោធន៍អ្វីខ្លះដែលសប្បាយសប្បាយរហូតមកដល់សព្វថ្ងៃនឹងថាតើលោកពូអាចចែកចាយមកកាន់ខ្ញុំបានដែលទេលោកពូ???

ខៈ

បាទសំរាប់បទពិសោធន៍របស់ខ្ញុំគឺថាបច្ចុប្បន្ននឹងគឺវាជឿនលឿងទៀតហើយចឹងហាសបាទសំរាប់គេដែលបានគេរកស៊ីនឹងគេគេមានកំលាំងហើយសំរាប់គេគឺគេរកស៊ីជឿនលឿងទៅមុខតាំងពីសង្គមហើយរហូតមកដល់បច្ចុប្បន្នលូវនឹងផងចឹងហាសបាទហើយសំរាប់អ្នកដែលគេបានរកស៊ីនឹងគេគេមានកំលាំងហើយសំរាប់គេគឺគេរកស៊ីជឿនលឿងទៅមុខចឹងហាសបាទ៕

កៈ

បាទលោកពូហើយចឹងសំរាប់ភាពសប្បាយរបស់លោកពូនឹងថាតើលោកពូមានអ្វីដែលជាភាពសប្បាយរបស់លោកពូផ្ទាល់ខ្លួនទេលោកពូ???

ខៈ

បាទនៅពេលដែលខ្ញុំនឹងបានឃើញនឹងសប្បាយយើងនឹងក៏បានសប្បាយចឹងទៅហាសបាទតែសំរាប់ជីវីភាពរបស់យើងនឹងគឺថាយើងមិនជាសូវជាធូរធារទេហាសបាទប្រសិនជាយើងធូរធារទៅយើងចេះតែសប្បាយនឹងគេចឹងទៅក៏ប៉ុនតែយើងមិនជាសូវធូរធារទេបាទហើយនៅពេលដែលយើងបានធូរធារចឹងទៅសំរាប់ប្រទេសជាតិនឹងក៏វាបានជឿនលឿនចឹងទៅហើយយើងក៏បានសប្បាយនឹងគេចឹងទៅហាសបាទ៕

កៈ

បាទលោកពូហើយចឹងសំរាប់លោកពូគឺលោកពូមិនជាសូវមានភាពសប្បាយរីករាយច្រើននោះទេមែនដែលទេលោកពូ???

ខៈ

បាទសំរាប់ខ្ញុំនឹងគឺខ្ញុំមិនជាសូវមានភាពសប្បាយរីករាយច្រើននោះទេគឺខ្ញុំនឹងមានភាពខ្វះខាតច្រើនណាស់ពីព្រោះអីនឹងសព្វថ្ងៃនឹងយើងដេកហូបតែកំលាំងរបស់កូនយើងចឹងហាសបាទ៕

កៈ

បាទហើយចឹងអរគុណច្រើនមែនទែនលោកពូសំរាប់ថ្ងៃនឹងហើយចឹងសំណួរដែលខ្ញុំនឹងសួរលោកពូគឺជាសំណួរចុងក្រោយបាទវាគឺជាសំណួរចុងក្រោយថាតើលោកពូមានពាក្យពេជ្រផ្តែលផ្តាំទៅកូនចៅជំនាន់ក្រោយរបស់លោកពូនៅពេលដែលគេបានលឺសំលេងរបស់លោ

កពូនៅក្នុងសំលេងមួយនេះហើយសំរាប់លោកពូមានអ្វីផ្តែលផ្តាំទៅកាន់កីនចៅរបស់លោពូនៅពេលដែលគាត់បានលឺសូរមានដែលទេលោកពូ???

ខ៖
បាទសំរាប់ខ្ញុំនឹងគឺថាកូនចៅដែលនៅខាងក្រោយក្រោយទៀតអោយគេបានជឿនលឿនទៅមុខចឹងទៅបាទអោយគេបានសប្បាយអោយអ្នកដែលនៅខាងក្រោយដូចថានៅក្នុងជំនាន់ខ្ញុំនឹងគឺគ្មានការសប្បាយរីករាយនោះទេគឺមានតែការកើតទុក្ខបាទនិយាយទៅគឺគ្មានការការសប្បាយរីករាយនោះទេគឺមានតែការកើតទុក្ខបាទហើយសំរាប់មកដល់ក្មេងក្មេងដែលនៅក្នុងជំនាន់ក្រោយនេះគឺគេគិតតែសប្បាយចឹងហាសក៏ប៉ុនតែវាបានផុសហើយចឹងហាសបាទពីព្រោះអីនឹងគឺខ្ញុំនឹងបានយកទៅអស់ហើយសំរាប់ការមានទុក្ខលំបាក់ចឹងហាសបាទហើយសំរាប់ភាពសប្បាយសប្បាយនឹងគឺទុក្ខសំរាប់អោយក្មេងក្មេងជំនាន់ក្រោយទៅហាសបាទ៕

ក៖
បាទហើយចឹងថាតើលោកពូមានអ្វីផ្តែលផ្តាំទៅកាន់កូនចៅរបស់លោកពូបន្ថែមទៀតដែលរឺទេដូចជាការខំប្រឹងប្រែងអីចឹងហាសលោកពូ???

ខ៖
បាទសំរាប់ខ្ញុំនឹងគ្មានអ្វីផ្តែលផ្តាំនោះទេគ្រាន់តែថាសំរាប់កូនចៅហើយនឹងកូនក្មួយនឹងសុំអោយពួកគេនឹងបានជឿនលឿនទៅចឹងទៅហាសបាទហើយនឹងជួយអបអរសំរាប់រដ្ឋាភិបាលផងលោកដែលលោកកំពុងកសាងសព្វថ្ងៃនឹងហាសបាទ៕

ក៖
បាទហើយចឹងសំរាប់អ្វីដែលលោកពូចង់ផ្តែលផ្តាំទៅកាន់កូនចៅរបស់លោកពូគឺថាអោយពួកគាត់នឹងខំប្រឹងដើម្បីធ្វើការងារដើម្បីអោយពួកគាត់មានភាពរីកចំរើននៅពេលអនាគតរបស់ពួកគេហើយចឹងហើយនឹងមានភាពប្រសើរឡើងមែនដែលទេលោកពូបាទហើយសំរាប់ថ្ងៃនឹងគឺខ្ញុំនឹងពិតជាសប្បាយចិត្តមែនដែលបានជួបជាមួយនឹងលោកពូហើយនឹងបានពិភាក្សាគ្នាជាមួយនឹងលោកពូហើយនឹងអរគុណច្រើនសំរាប់លោកពូដែលបានផ្តល់ឧកាសដែលបានអោយខ្ញុំបានជួបលោកពូហើយនឹងបានសំភាសន៍ជីវប្រវត្តរបស់លោកពូដែលនៅក្នុងជំនាន់ពោលពតបាទហើយក៏សង្ឃឹមថានៅពេលដែលកូនចៅរបស់លោកពូនៅក្នុងជំនាន់ក្រោយក្រោយនៅពេលដែលគេបានលឺសំលេងរបស់លោកពូសុំអោយគាត់នឹងបានយកសំលេងរបស់លោកពូនឹងយកទៅខិតខំទៅប្រឹងប្រែងដើម្បីអោយជីវិតរបស់គាត់បានល្អប្រសើរនៅក្នុងថ្ងៃអនាគតរបស់គាត់ផងដែលបាទហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំនឹងមានតែប៉ុននឹងលោកពូបាទហើយចឹងលោកពូមានចង់និយាយបន្ថែមទៀតដែលរឺទេលោកពូ???

ខ៖ បាទសំរាប់គឺខ្ញុំមានតែបិននឹងអត់មានអ្វីដែលនិយាយទៀតទេបាទហេហេហេ៕

ក៖
បាទចឹងសំរាប់ថ្ងៃនឹងគឺក្មួយមានតែបិននឹងលោកពូបាទចឹងថ្ងៃនឹងក្មួយមានតែបិននឹងចឹងក្មួ
យជំរាបលាណាលោកពូចឹងអរគុណច្រើនលោកពូ៕